**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :.............០១៧/២១.............ក.ប/ស.ជ.ណ.ខ.ល

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការបញ្ឈប់ការផ្តល់ "លិខិតអនុញ្ញាតចេញ-ចូល" ដល់រោងចក្រ សហគ្រាស និងសិប្បកម្ម នៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជម្រាបជូនលោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ព្រមទាំងសាធារណជនជ្រាបថា គិតត្រឹមម៉ោង ៨:០០រសៀលនេះ ក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានចេញ "លិខិតអនុញ្ញាតចេញ-ចូល" ចំនួន ១០ ៧៩៨ សន្លឹក។ យោងសេចក្តីសម្រេចលេខ ៤៩សសរ របស់រាជរដ្ឋាភិបាល ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងគោលការណ៍ឯកភាពរបស់គណៈកម្មការជាតិ **គ.ប.ខ** ក្រសួងសម្រេចបញ្ឈប់ការផ្តល់ "លិខិតអនុញ្ញាតចេញ-ចូល" ជូនរោងចក្រ សហគ្រាស និងសិប្បកម្មចាប់ពីពេលជូនដំណឹងនេះតទៅ។ លោក លោកស្រីជាម្ចាស់ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម អាចទៅស្នើសុំលិខិតអនុញ្ញាតឱ្យដំណើរការសកម្មភាពអាជីវកម្មពីអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត។

នៅពេលធ្វើដំណើរសូមលោក លោកស្រី និងបងប្អូនកម្មករនិយោជិត ដែលមានការអនុញ្ញាតឱ្យបន្តសកម្មភាពអាជីវកម្មយកជាប់ខ្លួនជានិច្ចនូវៈ

១. លិខិតអនុញ្ញាតឱ្យដំណើរការសកម្មភាពអាជីវកម្ម

២. ឯកសារបញ្ជាក់អំពីតួនាទីការងារ មុខរបរ ឬអាជីវកម្ម (បណ្ណកម្មករ ឬបណ្ណបុគ្គលិក)

៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតបញ្ជាក់ទីលំនៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ព្រមទាំងសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២១

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន:**

- គណៈកម្មការជាតិ គ.ប.ខ
- រដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាល
  "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល
  "ដើម្បីអនុវត្ត"